អនុវត្តដោយ

THE RBH NETWORK

giz Deutsche Gesellschaft für Internationale Zusammenarbeit (GIZ) GmbH

# សេចក្តីណែនាំស្តីពីការរាយការណ៍និរន្តរភាពសាជីវកម្មរបស់សហភាពអឺរ៉ុប

ព័ត៌មានពីបណ្តាញ Responsible Business Helpdesk (RBH) គឺដើម្បីផ្តល់ជាព័ត៌មាន និងណែនាំក្រុមហ៊ុនផ្គត់ផ្គង់ស្តីពីការត្រួតពិនិត្យភាពត្រឹមត្រូវផ្នែកសិទ្ធិមនុស្ស និងបរិស្ថាន។

## សាវតារ

សេចក្តីណែនាំស្តីពីការរាយការណ៍និរន្តរភាពសាជីវកម្ម (CSRD) របស់សហភាពអឺរ៉ុប ជួយបង្កើនប្រសិទ្ធភាព និងពង្រឹងវិធានពាក់ព័ន្ធនឹងព័ត៌មានបរិស្ថាន និងសង្គម ដែលក្រុមហ៊ុនត្រូវផ្សព្វផ្សាយ។ ច្បាប់ មិនអនុវត្តដោយផ្ទាល់នោះទេៈ រដ្ឋជាសមាជិកសហភាពអឺរ៉ុបត្រូវបញ្ចូលបទប្បញ្ញត្តិ CSRD នេះចូលទៅក្នុងច្បាប់ជាតិរបស់ខ្លួន។ សេចក្តីណែនាំនេះ ចូលជាធរមាននៅក្នុងខែមករា ឆ្នាំ2023 ប៉ុន្តែការអនុវត្តតាមបណ្តារដ្ឋជាសមាជិកសហភាពអឺរ៉ុប ចាប់ផ្តើមនៅក្នុងរយៈពេល 18 ខែក្រោយ ពោលគឺនៅក្នុងខែកក្កដា ឆ្នាំ2024។ ក្រុមហ៊ុនចំនួន 50.000 ត្រូវបានប៉ាន់ស្មានថានឹងត្រូវអនុលោមតាមសេចក្តីណែនាំ CSRD នេះ។

រយៈពេល និងវិសាលភាព




*ត្រូវតាមលក្ខណៈវិនិច្ឆ័យចំនួនពីរៈ តារាងតុល្យការ > 25 លានអឺរ៉ូ ការលក់ដុល > 50 លានអឺរ៉ូ ឬ បុគ្គលិក > 250 នាក់

**ត្រូវតាមលក្ខណៈវិនិច្ឆ័យយ៉ាងតិចចំនួនពីរៈ តារាងតុល្យការ > 450,000 អឺរ៉ូ ចំណូលពីការលក់ដុល > 900,000 អឺរ៉ូ ឬ បុគ្គលិក > 10 នាក់

***មានសាខាក្រុមហ៊ុន EU ឬក្រុមហ៊ុនបុត្រសម្ព័ន្ធ EU យ៉ាងតិចមួយ និងផលរបរដុលក្នុង EU > 150 លានអឺរ៉ូ

### CSRD ផ្តល់ ...

- **តម្លាភាព** ជូនដល់ភាគីពាក់ព័ន្ធរបស់ក្រុមហ៊ុន (វិនិយោគិន អតិថិជន សង្គមស៊ីវិល) ពាក់ព័ន្ធនឹងការអនុវត្តប្រកបដោយនិរន្តភាព និងឥទ្ធិពលលើមនុស្ស និងបរិស្ថាន។
- ក្របខណ្ឌសម្រាប់ការរាយការណដែលមាន**លក្ខណៈស៊ីគ្នា** ដែលស្របទៅនឹង CSDDD និង LkSG ទៅលើទិដ្ឋភាពវិសាលភាព និងកាតព្វកិច្ច ដោយធានានូវវិសាលភាពគ្រប់ដណ្តប់គ្រប់ជ្រុងជ្រោយ និងលុបបំបាត់នូវតម្រូវការរាយការណ៍ពីរដងផងដែរ។
- **របាយការណ៍ប្រហាក់ប្រហែល** ដែលមានភាពពាក់ព័ន្ធ ទុកចិត្តបាន ងាយស្រួលទាញយក និងប្រើប្រាស់។

### CSRD តម្រូវឱ្យ ...

**បញ្ចេញព័ត៌មាននិរន្តរភាពបែបគុណភាព និងបរិមាណលម្អិតដោយមានការធានាមានកម្រិត** (ឧ. ដោយសវនករភាគីទីបី ឬអ្នកបញ្ជាក់) ស្តីពីបរិស្ថាន អភិបាលកិច្ច និងសិទ្ធិមនុស្ស។ របាយការណ៍នេះ ត្រូវរួមបញ្ចូលហានិភ័យដែលក្រុមហ៊ុនធ្លាប់ជួបប្រទះ៖ យុទ្ធសាស្ត្រនិរន្តរភាព គោលដៅ គោលនយោបាយ កម្មវិធីលើកទឹកចិត្ត សូចនាករ និងការបញ្ចេញព័ត៌មានអំពីដំណើរការត្រួតពិនិត្យភាពត្រឹមត្រូវ។ វិសាលភាពនៃសេចក្តីណែនាំ CSRD ផ្តល់ជូននូវស្តង់ដារខុសៗគ្នាទៅតាមប្រភេទក្រុមហ៊ុនផ្សេងៗគ្នា។

### សំណួរសួរញឹកញាប់

*តើក្រុមហ៊ុនស្ថិតក្រោមសេចក្តីណែនាំនេះត្រូវរាយការណ៍យ៉ាងដូចម្តេច?*

ក្រុមហ៊ុនដែលត្រូវអនុវត្តតាមសេចក្តីណែនាំ CSRD ត្រូវរាយការណ៍តាមប្រព័ន្ធឌីជីថលស្របតាម ស្តង់ដាររាយការណ៍និរន្តរភាពសហភាពអឺរ៉ុប (ESRS) ក្នុងទម្រង់អេឡិចត្រូនិកតែមួយរបស់សហភាពអឺរ៉ុប (ESEF)។ ស្តង់ដារនេះ ត្រូវបានបង្កើតឡើងដោយក្រុមការងារផ្តល់យោបល់អំពីការរាយការណ៍ហិរញ្ញវត្ថុរបស់សហភាពអឺរ៉ុប (EFRAG)។

*តើក្រុមហ៊ុនស្ថិតក្រោមសេចក្តីណែនាំនេះត្រូវរាយការណ៍នៅពេលណា និងទៅនរណា?*

របាយការណ៍ដែលតម្រូវនោះ គឺត្រូវដាក់ជូនជារៀងរាល់ឆ្នាំ សម្រាប់ជាផ្នែកមួយនៃរបាយការណ៍គ្រប់គ្រង។ របាយការណ៍នេះ ត្រូវដាក់ជូនស្របទៅតាមលក្ខខណ្ឌបច្ចេកទេសរបស់រដ្ឋជាសមាជិកសភាអឺរ៉ុបនីមួយៗ។ បន្ថែមពីនេះ វេទិកាឌីជីថលរបស់សហភាពអឺរ៉ុប (European Single Access Point) នឹងត្រូវរៀបចំបង្កើតឡើងសម្រាប់ការដាក់របាយការណ៍។

*តើរបាយការណ៍ CSRD នឹងត្រូវវាយតម្លៃដូចម្តេច?*

ព័ត៌មាន នឹងត្រូវផ្ទៀងផ្ទាត់ដោយសវនករឯករាជ្យ និងអាចត្រួតពិនិត្យដោយភាគីពាក់ព័ន្ធផ្សេងៗ (ឧ. អង្គការមិនមែនរដ្ឋាភិបាល)។

*តើក្រុមហ៊ុនស្ថិតក្រោមសេចក្តីណែនាំនេះនឹងជួបផលវិបាកអ្វីក្នុងករណីមិនអនុលោមតាម?*

ការមិនអនុលោមភាព អាចផ្តល់ផលវិបាកអវិជ្ជមានសម្រាប់ក្រុមហ៊ុនស្ថិតក្រោមសេចក្តីណែនាំ ដូចជាទណ្ឌកម្មផ្លូវច្បាប់ មតិយោបល់សវនកម្មអវិជ្ជមានលើរបាយការណ៍ហិរញ្ញវត្ថុ និងការប៉ះពាល់ទៅដល់កេរ្តិ៍ឈ្មោះ។ ការដាក់ទណ្ឌកម្មដោយសារការមិនអនុលោមតាមនេះនឹងត្រូវកំណត់ដោយរដ្ឋជាសមាជិកសហភាពអឺរ៉ុប។

giz



## ទំនាក់ទំនង

Paul Steimer អ្នកសម្របសម្រួលបណ្តាញសម្រាប់បណ្តាញ RBH
@ Initiative for Global Solidarity

ទូរសព្ទ៖ +49228 4460 4913
paul.steimer@giz.de

THE RBH NETWORK

## ផលវិបាកដែលអាចកើតឡើងចំពោះក្រុមហ៊ុនផ្គត់ផ្គង់

**ការចូលរួមពីក្រុមហ៊ុនផ្គត់ផ្គង់កាន់តែច្រើន៖** មានការពិគ្រោះយោបល់ ការសម្ភាសន៍ ការស្ទង់មតិ យន្តការបណ្តឹង និងទំនាក់ទំនងក្រៅផ្លូវការកាន់តែច្រើន (ដូចជាកិច្ចប្រជុំ ឬកិច្ចប្រជុំតុមូល) ដើម្បីផ្តល់ព័ត៌មានដល់អ្នកទិញអំពីការរាយការណ៍និរន្តរភាព។

**ពង្រឹងការប្រមូលទិន្នន័យ៖** ក្រុមហ៊ុនផ្គត់ផ្គង់ ត្រូវវាយតម្លៃអត្ថិភាពទិន្នន័យស្តីពីសូចនាករ CSRD ពាក់ព័ន្ធ។ ប្រព័ន្ធរាយការណ៍នេះ អាចនឹងត្រូវពង្រីកវិសាលភាពបន្ថែម។

**យន្តការតាមដាន៖** ត្រួតពិនិត្យការប្រកាន់ខ្ជាប់ទៅនឹងយន្តការត្រួតពិនិត្យភាពត្រឹមត្រូវផ្នែកសិទ្ធិមនុស្ស និងបរិស្ថាន អាចនឹងកើនឡើងក្នុងទម្រង់ជាសវនកម្ម ឬអធិការកិច្ច (ភាគីទីបី)។

**ការជ្រើសរើសក្រុមហ៊ុនផ្គត់ផ្គង់ដោយផ្ទាល់៖** អ្នកទិញ នឹងពិចារណាទៅលើការប្រកាន់ខ្ជាប់ចំពោះស្តង់ដារសិទ្ធិមនុស្ស និងបរិស្ថាន ក៏ដូចជាលទ្ធភាពក្នុងការផ្ទៀងផ្ទាត់ក្នុងការជ្រើសរើសក្រុមហ៊ុនផ្គត់ផ្គង់របស់ខ្លួន។

### ការត្រៀមលក្ខណៈរបស់ក្រុមហ៊ុន?

ការវិភាគដោយ World Benchmarking Alliance (2024) បានបង្ហាញ **ថាក្រុមហ៊ុនដែលស្ថិតក្រោមវិសាលភាព CSRD ចំនួនមិនដល់ 30%** នោះទេដែលមកពីប្រទេសកំពុងអភិវឌ្ឍន៍ **គឺស្ថិតនៅក្នុងដំណើរការ**នៃការរាយការណ៍។

### ធនធានបន្ថែម

1. ព័ត៌មានលម្អិតអំពី CSRD ដោយ PWC៖ Worldwide impact of CSRD – are you ready?
2. ទិដ្ឋភាពទូទៅដោយ BSR៖ Making Sense of CSDDD and CSRD

## ឱកាសសម្រាប់ក្រុមហ៊ុនផ្គត់ផ្គង់

**វេទិកាសម្រាប់ការចូលរួម៖** អ្នកទិញត្រូវពិចារណាអំពីការយល់ឃើញរបស់ភាគីពាក់ព័ន្ធ។

**ការបង្កើតទំនាក់ទំនងរវាងអ្នកទិញ-ក្រុមហ៊ុនផ្គត់ផ្គង់៖** បង្កើនកិច្ចសន្ទនាជាមួយនឹងអ្នកទិញ អាចពង្រឹងទំនុកចិត្ត ការទុកចិត្ត ព្រមទាំងអាចជំរុញទំនាក់ទំនងរយៈពេលវែងផងដែរ។

**ភាពធន់៖** ការរាយការណ៍ល្អប្រសើរ ជួយលើកកម្ពស់ការយល់ដឹងរបស់ក្រុមហ៊ុនអំពីហានិភ័យ HREDD និងពង្រឹងការគ្រប់គ្រងហានិភ័យ

### *តើខ្ញុំអាចធ្វើអ្វីខ្លះក្នុងនាមជាក្រុមហ៊ុនផ្គត់ផ្គង់?*

- បែងចែកធនធានឱ្យបានគ្រប់គ្រាន់ ដើម្បីស្វែងយល់ និងអនុលោមឱ្យបានជាមុននូវទិដ្ឋភាពផ្លូវច្បាប់
- បន្ត**កត់ត្រាជាប្រចាំ**នូវដំណើរការដើម្បីអាចផ្តល់នូវព័ត៌មានចាំបាច់
- **ពិភាក្សា**អំពីបញ្ហា និងផែនការអនុវត្ត**ជាមួយនឹងអតិថិជនរបស់អ្នក** រួចប្រាប់**អំពីតម្រូវការគាំទ្រ** ដើម្បីឱ្យស្របទៅតាមលក្ខខណ្ឌរបស់ពួកគេ
- ពិនិត្យប្រ**ព័ន្ធគ្រប់គ្រង និងកម្មវិធីបញ្ជាក់**ដែលមានស្រាប់
- ដឹងអំពីហានិភ័យនៅក្នុងប្រតិបត្តិការអាជីវកម្មរបស់ខ្លួន និងខ្សែច្រវាក់ផ្គត់ផ្គង់ ដើម្បីធ្វើការប្រៀបធៀបព័ត៌មានជាមួយនឹងលទ្ធផលរកឃើញរបស់សវនករ
- ស្វែងរកឱកាសក្នុងការ**ជំរុញឱ្យអ្នកបង្កើតគោលនយោបាយចូលរួម** ដើម្បីកែសម្រួលគោលនយោបាយឱ្យស្របតាមបរិបទ
- ស្វែងរកជំនួយរចនាសម្ព័ន្ធគាំទ្រ ដូចជា Responsible Business Helpdesks និងក្រុមហ៊ុនផ្តល់សេវាផ្សេងៗ